# បោះឆ្នោតមុនពេលកំណត់ដោយ សន្លឹកឆ្នោត សម្រាប់ពលរដ្ឋអវត្តមាន

VOTE 2024

នៅរដ្ឋ*Minnesota*អ្នកពុំចាំបាច់រង់ចាំទាល់តែដល់ថ្ងៃបោះឆ្នោតឡើយ-បោះឆ្នោតមុនពេលកំណត់ជាមួយនឹងសន្លឹកឆ្នោតសម្រាប់ពលរដ្ឋអវត្តមាន!

## បោះឆ្នោតមុនពេលកំណត់ដោយផ្ទាល់

អ្នកអាចបោះឆ្នោតជាមួយនឹងសន្លឹកឆ្នោតសម្រាប់ពលរដ្ឋអវត្តមាននៅការិយាល័យបោះឆ្នោតក្នុងមូលដ្ឋានរបស់អ្នកនៅក្នុងរយៈពេល 46 ថ្ងៃមុនថ្ងៃបោះឆ្នោត។សូមចូលទៅកាន់វេបសាយត៍ mnvotes.gov ដើម្បីទទួលព័ត៌មានអំពីពេលវេលានិងទីតាំង។

## បោះឆ្នោតមុនពេលកំណត់តាមសំបុត្រ

អ្នកក៏អាចដាក់ពាក្យស្នើសុំឱ្យបញ្ជូនសន្លឹកឆ្នោតសម្រាប់ពលរដ្ឋអវត្តមានតាមលិខិតផងដែរ។អ្នកត្រូវប្រគល់សន្លឹកឆ្នោតរបស់អ្នកនៅត្រឹមថ្ងៃបោះឆ្នោត។

- ដាក់ពាក្យស្នើសុំសន្លឹកឆ្នោតនៅពេលណាមួយនៅក្នុងឆ្នាំ តាមវេបសាយត៍mnvotes.gov =។មន្ត្រីបោះឆ្នោតនឹងផ្ញើឯកសារបោះឆ្នោតនៅពេលមានសន្លឹកឆ្នោត (សូមមើលទំព័រក្រោយសម្រាប់កាលបរិច្ឆេទ)។

- សូមអានសេចក្តីណែនាំដែលភ្ជាប់ជាមួយសន្លឹកឆ្នោតរបស់អ្នកដោយយកចិត្តទុកដាក់! សន្លឹកឆ្នោតរបស់អ្នកនឹងក្លាយជាសន្លឹកឆ្នោតអត់បានការប្រសិនបើអ្នកមិនបំពេញគ្រប់ទម្រង់បែបបទទេ។

- អ្នកនឹងត្រូវការសាក្សីនៅពេលអ្នកបោះឆ្នោតនិងបំពេញសន្លឹកឆ្នោតរបស់អ្នក។សាក្សីអាចជាអ្នកបោះឆ្នោតនៅរដ្ឋMinnesotaដែលបានចុះឈ្មោះត្រឹមត្រូវឬជាសាការី។សាក្សីរបស់អ្នកត្រូវចុះហត្ថលេខានៅលើស្រោមសំបុត្រហត្ថលេខានិងដាក់អាសយដ្ឋានរបស់គាត់។

**កាលបរិច្ឆេទឆ្នាំ 2024**

**ការបោះឆ្នោតបឋម**
ថ្ងៃអង្គារ៍ទី*13* ខែសីហា

**ការបោះឆ្នោតសម្រាប់ពលរដ្ឋអវត្តមាន**
បោះឆ្នោតតាមសំបុត្រ ឬ ដោយផ្ទាល់ថ្ងៃទី*20* ខែកញ្ញា រហូតដល់ថ្ងៃទី*4* ខែវិច្ឆិកា

**ចុះឈ្មោះបោះឆ្នោត**
ចុះឈ្មោះជាមុននៅត្រឹមថ្ងៃ ទី*15* ខែតុលា ដើម្បីសន្សំ សំចៃពេលវេលានៅថ្ងៃ បោះឆ្នោត។

**ថ្ងៃបោះឆ្នោត**
ថ្ងៃអង្គារ៍ទី*5* ខែវិច្ឆិកា

ការិយាល័យលេខាធិការរដ្ឋ *Minnesota*
*mnvotes.gov • 1-877-600-VOTE*

# បោះឆ្នោតមុនពេលកំណត់ដោយសន្លឹកឆ្នោត សម្រាប់ពលរដ្ឋអវត្តមាន

VOTE 2024

I WILL VOTE

.... តពីទំព័រមុខ

• ប្រសិនបើអ្នកមិនទាន់បានចុះឈ្មោះបោះឆ្នោតទេ អ្នកនឹងទទួលបានពាក្យស្នើសុំចុះឈ្មោះបោះឆ្នោតនៅក្នុងឯកសាររបស់អ្នក។ ដើម្បីចុះឈ្មោះសូមបង្ហាញ សាក្សីរបស់អ្នកនូវឯកសារបញ្ជាក់អត្តសញ្ញាណណាមួយដែលមានរៀបរាប់នៅក្នុងសេចក្តីណែនាំ។ សាក្សី របស់អ្នកត្រូវគូសឯកសារបញ្ជាក់អត្តសញ្ញាណមួយដែលអ្នកបានបង្ហាញពួកគាត់នៅលើស្រោមសំបុត្រហត្ថលេខា។

• បន្ទាប់ពីអ្នកបញ្ចប់សូមផ្ញើសន្លឹកឆ្នោតនិងទម្រង់ត្រឡប់ទៅវិញភ្លាមៗ។សន្លឹកឆ្នោតរបស់អ្នកនឹងទុកជាអត់បានការប្រសិនបើត្រូវបានទទួលនៅបន្ទាប់ពីថ្ងៃបោះឆ្នោត។អ្នកក៏អាចប្រគល់សន្លឹកឆ្នោតដោយផ្ទាល់ដល់ការិយាល័យបោះឆ្នោតដែលបានផ្ញើសន្លឹកឆ្នោតទៅឱ្យអ្នក។

## តាមដានសន្លឹកឆ្នោតរបស់អ្នក

រាល់សន្លឹកឆ្នោតសម្រាប់ពលរដ្ឋអវត្តមានទាំងអស់ដែលបានទទួលទាន់ពេលវេលានិងបានបំពេញទម្រង់បែបបទត្រឹមត្រូវនឹងត្រូវរាប់ជាសន្លឹកឆ្នោតបានការ។សូមចូលមើលវេបសាយត៍ mnvotes.gov ដើម្បីតាមដានស្ថានភាពសន្លឹកឆ្នោតរបស់អ្នកនិងបញ្ជាក់ថាសន្លឹកឆ្នោតនោះបានទទួលនិងរាប់ជាសន្លឹកឆ្នោតបានការ។

| កាលបរិច្ឆេទឆ្នាំ**2024** | **ការបោះឆ្នោតបឋម** | **ការបោះឆ្នោតសកល** |
|---|---|---|
| **សន្លឹកឆ្នោតដែលបានបញ្ជូនកំពុងចាប់ផ្តើម** | ថ្ងៃសុក្រទី28 ខែមិថុនា | ថ្ងៃសុក្រទី20 ខែកញ្ញា |
| **ដែលបានណែនាំឱ្យអ្នកដាក់ពាក្យស្នើសុំពីមុន** | ថ្ងៃសុកទី12 ខែកក្កដា | ថ្ងៃសុក្រទី4 ខែកញ្ញា |
| **ថ្ងៃខែផុតកំណត់សម្រាប់ទទួលសន្លឹកឆ្នោត** | ថ្ងៃបោះឆ្នោត ថ្ងៃអង្គារ៍ទី13 ខែសីហា | ថ្ងៃបោះឆ្នោត ថ្ងៃអង្គារ៍ទី5 ខែវិច្ឆិកា |

## ការិយាល័យលេខាធិការរដ្ឋ *Minnesota*
## *mnvotes.gov • 1-877-600-VOTE*